# សេចក្តីថ្លែងការណ៍របស់ដៃគូអភិវឌ្ឍន៍

## របៀបវារៈទី IIIC: ប្រសិទ្ធភាពជំនួយសម្រាប់ប្រទេសកម្ពុជា ~ វឌ្ឍនៈភាព បញ្ហាប្រឈម និងអនុសាសន៍

## ថ្លែងដោយលោកស្រី Eva Asplund នាយកប្រចាំប្រទេស នៃទីភ្នាក់ងារ SIDA

## តំណាងដៃគូអភិវឌ្ឍន៍ នៅក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣

## ភ្នំពេញ ថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ២០១០

***-សូមគោរព ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ***

***-ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរពរាប់អាន!***

ក្នុងនាមដៃគូរអភិវឌ្ឍន៍នានា ខ្ញុំមានកិត្តិយសថ្លែងនូវសេចក្តីថ្លែងការណ៍ស្តីពីប្រសិទ្ធភាពជំនួយក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍកម្ពុជាលើកទី ៣ (CDCF) នេះ ។

តួនាទីរបស់យើងខ្ញុំក្នុងនាមជាដៃគូរអភិវឌ្ឍន៍ គឺដើម្បីគាំទ្រដល់ប្រសិទ្ធិភាពការអភិវឌ្ឍន៍ និងការសំរេចបាននូវគោលដៅអភិវឌ្ឍសហស្សវត្សរកម្ពុជាតាមរយៈការផ្តល់នូវការប្តេជ្ញាចិត្តជាអន្តរជាតិទាំងបរិមាណ និងគុណភាពជំនួយ ។

រាជរដ្ឋាភិបាលកម្ពុជា និងដៃគូរអភិវឌ្ឍន៍របស់ខ្លួនបានបន្តកែលំអប្រព័ន្ធនានា ដែលតាមរយៈនោះជំនួយត្រូវបានគ្រប់គ្រង បើទោះជាមានផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ចពិភពលោកក៏ដោយ ។ ការកែលំអទាំងនោះ រួមមានៈ ភាពជាម្ចាស់របស់រដ្ឋាភិបាល តាមរយៈការបង្កើន និងការកែលំអផែនការតាមវិស័យ ការផ្សារភ្ជាប់ដៃគូអភិវឌ្ឍន៍ទៅនឹងយុទ្ធសាស្ត្រ និងអាទិភាពជាតិ និងការពង្រឹងនូវក្របខ័ណ្ឌសុច្ចនាករតាមដានរួមគ្នា សម្រាប់ការគ្រប់គ្រងលទ្ធផល និងគណនេយ្យភាពទៅវិញទៅមក ។ នេះជាការបង្ហាញអោយឃើញពីវឌ្ឍនៈភាពយ៉ាងល្អ ហើយនៅមានកិច្ចការជាច្រើនទៀតដែលត្រូវបំពេញ ដើម្បីប្រែក្លាយវឌ្ឍនៈភាពនេះអោយទៅជា លទ្ធផលនៃការអភិវឌ្ឍ ។

របាយការណ៍ស្តីពីប្រសិទ្ធភាពជំនួយសម្រាប់ប្រទេសកម្ពុជាឆ្នាំ ២០១០ (2010 AER) ផ្តល់នូវមូលដ្ឋានដ៏សមស្រប សម្រាប់បរិយាយបង្ហាញទិសដៅនានានៃគោលនយោបាយនាពេលអនាគត ។

របាយការណ៍ស្តីពីប្រសិទ្ធភាពជំនួយសម្រាប់ប្រទេសកម្ពុជាឆ្នាំ ២០១០ (2010 AER) កសាងឡើងនៅក្រោមប្រភពគុណភាព និងបរិមាណ ដ៏ច្រើនសន្ធឹកសន្ធាប់ ។ ប្រព័ន្ធទិន្នន័យ នៃជំនួយអភិវឌ្ឍន៍ បរទេសសម្រាប់កម្ពុជាដែលជាការអនុវត្តដ៏ល្អជាសកល ផ្តល់នូវទិន្នន័យសម្រាប់ការសន្ទនា ដោយមានមូលដ្ឋានច្បាស់លាស់ ។

ការផ្តល់មតិយោបល់នានាពីក្រុមការងារបច្ចេទេស ជួយអោយប្រសិទ្ធភាពជំនួយក្នុងវិស័យនានាក្លាយជាការពិត ។ លើសពីនេះទៅទៀត របាយការណ៍លើកឡើង នូវបញ្ហាដ៏ត្រឹមត្រូវ ថាតើសកម្មភាពដែលជាប់ពាក់ព័ន្ធប្រសិទ្ធភាពជំនួយ ពិតជាបានធ្វើអោយមានការអភិវឌ្ឍសមត្ថភាព កាត់បន្ថយចំណាយប្រតិបត្តិការ និងចូលរួមចំណែកដល់លទ្ធផលនៃការអភិវឌ្ឍ ដូចដែលបានគ្រោងដែរឬទេ ។

យើងត្រូវបោះជំហ៊ានទៅមុខ ហើយបច្ចុប្បន្នយើងត្រូវធានាថាយើងរក្សានូវសន្ទុះរបស់យើង ជាការពិតណាស់បង្កើននូវការងាររបស់យើង ដើម្បីយើងទាំងអស់គ្នាអាចទទួលបាននូវលទ្ធផលនៃការអភិវឌ្ឍដែលយើងចង់បាន ។ ការឯកភាពគ្នានេះ រាប់បញ្ចូលទាំងការធ្វើសមាហរណកម្មនៃការធ្វើផែនការ ការគ្រប់គ្រងការរៀបចំធ្វើថវិកា និងជំនួយ ការបង្កើនការប្រើប្រាស់អភិក្រមតាមកម្មវិធី (PBAs) និងកិច្ចខិតខំបង្កើនគណនេយ្យភាពទៅវិញទៅមក រួមទាំងការត្រួតពិនិត្យពីរដ្ឋសភា និងការចូលរួមពីប្រជាពលរដ្ឋ ។

## បង្កើនការធ្វើសមាហរណកម្មនៃការធ្វើផែនការ ការធ្វើថវិកា និងការគ្រប់គ្រងជំនួយ

ដៃគូអភិវឌ្ឍន៍កត់សំគាល់នូវការរៀបចំការងារដែលត្រូវធ្វើសម្រាប់ការធ្វើសម្មាហរណកម្មនៃផែនការជាតិ ថវិកាជាតិ និងការគ្រប់គ្រងជំនួយ ហើយនាពេលបច្ចុប្បន្នស្វែងរកការពន្លឿនវឌ្ឍនៈភាពនៅក្នុងដំណើការកណ្តាលនេះ។ រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍បានយល់ព្រមគ្នានៅឯវេទិកាសហប្រត្តិបត្តិការអភិវឌ្ឍកម្ពុជាលើទី២ ថាការពង្រឹងការធ្វើសម្មាហរណកម្មថ្នាក់កណ្តាលនៃការធ្វើផែនការយុទ្ធសាស្រ្ត ការធ្វើថវិកា និងការគ្រប់គ្រងជំនួយ គឺមានសារៈសំខាន់ណាស់ សម្រាប់ការសំរេចបាននូវលទ្ធផលនៃការអភិវឌ្ឍ តាមរយៈការអភិក្រមសម្របសម្រួលយ៉ាងល្អ ជាច្រើនឆ្នាំ ដើម្បីអនុវត្តនូវផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិសម្រាប់ឆ្នាំ ២០០៩-២០១៣ ។ វឌ្ឍនៈភាពរហូតមកដល់ពេលបច្ចុប្បន្នបានត្រូវផ្តោតជាសំខាន់ទៅលើការបង្កើតឡើងនូវដំណើរការ ។

ដើម្បីធានាអោយសមាហរណកម្មនេះប្រព្រឹត្តទៅ ដោយគ្មានការពន្យាពេល ដៃគូអភិវឌ្ឍន៍ចង់បាននូវភាពជឿនលឿនក្នុងជំហ៊ានបន្ទាប់ដ៏សំខាន់ក្នុងដំណើរការ និងការអះអាងជាថ្មីនូវការបន្តការគាំទ្ររបស់យើងខ្ញុំចំពោះដំណើរការ ។ ជាពិសេស ដៃគូអភិវឌ្ឍន៍ចង់បាននូវការបញ្ជាក់ពីក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដូចតទៅៈ

- តើអ្វីជាវឌ្ឍនៈភាព ដែលបានធ្វើឡើងដោយគណៈកម្មការអន្តរក្រសួង តើការសិក្សាវិនិច្ឆ័យដែលបានលើកឡើងនៅកិច្ចប្រជុំលើទី១៤ របស់ក្រុមការងារបច្ចេកទេស P&H បានចាប់ផ្តើមទេ ហើយតើជំហ៊ានបន្តបន្ទាប់អ្វីខ្លះដែលត្រូវបានរៀបចំ ?

- តើអ្វីទៅជាតួនាទី និងការរួមចំណែកនៃដំណើរការកម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយនិងផែនការយុទ្ធសាស្ត្រថវិកា ក្នុងឋានៈជាឧបករណ៍សម្រាប់ការគ្រប់គ្រងប្រភពធនធនទាំងអស់ ?
- តើអ្វីទៅជាតួនាទីរបស់កម្មវិធីវិនិយោគសាធារណៈ នៅក្នុងបរិយាកាសផ្លាស់ប្តូរ នៃការធ្វើផែនការ និងការធ្វើថវិកា ?

**អភិក្រមតាមកម្មវិធីបន្ថែម និងកាន់តែប្រសើរ**

ដៃគូអភិវឌ្ឍន៏គាំទ្រចំពោះទិសដៅគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីពង្រឹងភាពជាដៃគូតាមរយៈការប្រើប្រាស់អភិក្រមផ្តោតលើកម្មវិធី (PBAs) ដែលជំរុញប្រសិទ្ធភាពភាពជាដៃគូ ពង្រឹងភាពជាម្ចាស់ អភិវឌ្ឍសមត្ថភាព ពង្រឹងប្រព័ន្ធក្នុងប្រទេស គ្រប់គ្រងតាមរូបភាពផ្សេងៗគ្នានៃគំរូផ្តល់ជំនួយ និងធានានូវគណនេយ្យភាពទៅវិញទៅមកសម្រាប់លទ្ធផលនៃការអភិវឌ្ឍ ។

ដូចដែលបានលើកឡើងនៅឯកិច្ចប្រជុំ GDCC លើកទី ១៦ កាលពីខែមុន ហើយស្របទៅតាមសូចនាករត្រួតពិនិត្យរួមគ្នានៃភាពជាគ្ញែ និងសុខដុមនីកម្ម ឆ្នាំ២០១០ យើងនឹងធ្វើការរួមគ្នាដើម្បីធានាដល់ការបង្កើនការប្រើប្រាស់អភិក្រមផ្តោតលើកម្មវិធីមូលដ្ឋាន (PBAs) ពង្រឹងការប្រើប្រាស់ផែនការ ការអនុវត្តថវិកា ការធ្វើរបាយការណ៍ និងការត្រួតពិនិត្យមើលប្រព័ន្ធរដ្ឋាភិបាល និងបង្កើនសុខដុមនីកម្ម នៃកិច្ចខិតខំប្រឹងប្រែងផ្តល់ជំនួយបច្ចេកទេស របស់ដៃគូរអភិវឌ្ឍន៏ ។

- យើងខ្ញុំគាំទ្រភាពជាអ្នកដឹកនាំរបស់ CRDB/CDC នៅក្នុងការបង្ហាញពីជំហ៊ានបន្តបន្ទាប់ចាំបាច់ដើម្បីធ្វើអោយដំណើរការទៅមុខ ។ ដៃគូអភិវឌ្ឍន៏ស្នើ CRDB/CDC ដោយមានការគាំទ្រពី P&H TWG ដឹកនាំគោលដៅ " PBA គ្លីនិក " ជាច្រើនតាមក៏រិតវិស័យ និងឯកភាពការពង្រឹងការអនុវត្តតាមផែនទីបង្ហាញផ្លូវ ។ បញ្ហានេះនឹងជួយបង្កើតនូវរបៀបការធ្វើដៃគូតាមវិស័យ ដែលអាចធ្វើការងារកាន់តែមានប្រសិទ្ធភាព និងប្រភេទសកម្មភាពជាក់លាក់នានា សមត្ថភាព ដែលត្រូវតំរូវទៅតាមវិស័យពាក់ព័ន្ធ ។

តាមរយៈការសន្យាជាសកលស្តីពីប្រសិទ្ធភាពជំនួយ រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៏ បានយល់ព្រៀងគ្នាថា ការប្រើប្រាស់ប្រព័ន្ធរបស់ប្រទេសគួរតែជាជម្រើសដំបូងគេ ។ ដរាបណាជំនួយត្រូវបានផ្តល់តាមរយៈប្រព័ន្ធ និងរចនាសម្ព័ន្ធខ្សែបណ្តោយ វានឹងរារាំងដល់ការអភិវឌ្ឍសមត្ថភាព ព្រមទាំងបន្ថយភាពជាម្ចាស់ជាតិ និងគណនេយ្យភាពជាតិ ។

ទោះជាយ៉ាងណាក៏ដោយ ពុំមានយោលបល់ឯកភាព ថាតើលក្ខ័ណ្ឌជាមូលដ្ឋានដើម្បីគាំទ្រដល់ការប្រើប្រាស់ប្រព័ន្ធរបស់ប្រទេសដែលមានស្រាប់ ទាក់ទងនិងសមត្ថភាពបច្ចុប្បន្ន និងសេចក្តីសុចរឹត នៃប្រព័ន្ធដើម្បីគ្រប់គ្រងលំហូរទាំងនេះ និងទំនាក់ទំនងដៃគូ និងក្នុងការធានាថាក៏រិតលទ្ធផលពាក់ព័ន្ធត្រូវបានសម្រេច ។ ការបង្កើនកិច្ចប្រឹងប្រែង គឺចាំបាច់ណាស់ដើម្បីកសាងនូវអភិក្រមសម្របសម្រួលមួយ ក្នុងការកសាងសមត្ថភាពនៃប្រព័ន្ធរបស់ប្រទេស ហើយជាការគាំទ្រដល់បញ្ហានេះ បង្កើនការប្រើប្រាស់របស់អភិវឌ្ឍដៃគូនូវប្រព័ន្ធទាំងនេះ ។ ចំណុចចាប់ផ្តើម អាចជាការសិក្សាវាយតម្លៃទៅលើរចនាសម្ព័ន្ធ និងប្រព័ន្ធជាតិសម្រាប់ការអនុវត្តជំនួយនៅកម្ពុជា ។ យើងគាំទ្រក្រុមការងារបច្ចេកទេសជាដៃគូរ និងសុខដុមនីយកម្ម P& H TWG ក្នុងការធ្វើអោយការងារនេះដំណើរការទៅមុខ នឹងធ្វើការងារជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីពង្រីកផែនទីអនុវត្តជាបឋម និងយល់ស្របតាមផែនការសកម្មភាព សម្រាប់ការងារនាពេលអនាគត ។

- តើ CDC អាចផ្តល់ទស្សនៈជាបឋមថាតើការងារនេះ នឹងធ្វើអោយដំណើរការទៅយ៉ាងដូចម្តេច ?

បន្ថែមពីនេះទៀត ដៃគូអភិវឌ្ឍន៏ស្វាគមន៏ការផ្សព្វផ្សាយទូលំទូលាយ និងការអនុម័តគោលការណ៏ណែនាំស្តីពីវិធាន និងការគ្រប់គ្រងកិច្ចសហប្រតិបត្តិការបច្ចេកទេស ២០០៨ និងការធ្វើសមាហរណកម្មរបស់ពួកគេចូលទៅក្នុងគោលនយោបាយរបស់ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ស្តីពីការអភិវឌ្ឍនសមត្ថភាព ។ បញ្ហានេះនឹងគាំទ្រដល់គោលបំណងនៃការពង្រឹងការផ្សាភ្ជាប់ រវាងសហប្រតិបត្តិបច្ចេកទេស និងការអភិវឌ្ឍនសមត្ថភាព ។ ដោយការអភិវឌ្ឍសមត្ថភាព គឺជាកត្តាគន្លឹះ ក្នុងការអភិវឌ្ឍកិច្ចសហប្រតិបត្តិការ ការប្រើប្រាស់ជំនួយបច្ចេកទេសប្រកបដោយប្រសិទ្ធភាពនោះ ដូចនេះត្រូវតែបានធ្វើអោយមានភាពជឿនលឿននៅក៏រិតវិស័យ ក៏ដូចជាតាមរយៈកំណែទំរង់ស្នូល ដូចជា ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអភិវឌ្ឍន៏ប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ និងក្នុងរដ្ឋបាលសាធារណៈ កាន់តែទូលំទូលាយ ។ យើងម្នាក់ៗត្រូវ ទទួលខុសត្រូវដល់ការធ្វើអោយកិច្ចការនេះកើតមានឡើង ។

### បង្កើនកិច្ចខិតខំក្នុងគណនេយ្យភាពទៅវិញទៅមក — ការចូលរួម នៃសង្គមស៊ីវិល និងរដ្ឋសភា ក្នុងស្ថាបត្យកម្មជំនួយ

តួនាទីនៃសង្គមស៊ីវិលក្នុងការផ្តល់អោយ នូវប្រសិទ្ធភាពជំនួយត្រូវបានឆ្លុះបញ្ចាំងក្នុង 2010 AERប៉ុន្តែលទ្ធភាពសក្តានុពល នៃការចូលរួមរបស់ពួកគេក្នុងរបៀបវារៈប្រសិទ្ធភាពជំនួយនាពេលបច្ចុប្បន្ននេះ ពុំទាន់សំរេចបានពេញលេញទេ ។ ការត្រួតពិនិត្យពីរដ្ឋសភា និងការចូលរួមពីប្រជាពលរដ្ឋ ឬសង្គមស៊ីវិលនៅក្នុងការរៀបរាង

គោលនយោបាយជាតិ សុច្ឆនាករតាមដានរួមគ្នា និងថវិកា នឹងគាំទ្រដល់កិច្ចប្រឹងប្រែងឆ្ពោះទៅរកអភិបាលកិច្ចប្រជាធិប្បតេយ្យ ។ ដៃគូរអភិវឌ្ឍន៍ នឹងបន្តធ្វើការងារជាមួយបណ្តាញ សង្គមស៊ីវិល ឬ អង្គការក្រៅរដ្ឋាភិបាល ដើម្បីអភិវឌ្ឍសមត្ថភាពរបស់ពួកគេ អោយចូលរួមក្នុងការគ្រប់គ្រងជំនួយ និងគាំទ្រអង្គការសង្គមស៊ីវិល ដើម្បីសម្រេចបាននូវការប្តេជ្ញាផ្ទាល់ខ្លួនរបស់ពួកគេ ក្នុងការធ្វើជាដៃគូរដែលមានគណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាពក្នុងការអភិវឌ្ឍន៍ ។

**ក្នុងគោលបំណងដោះស្រាយបញ្ហានេះ ៈ**

- យើងខ្ញុំស្វាគមន៍ចំពោះទស្សនៈរបស់រដ្ឋាភិបាលដែលបានលើកឡើងនៅឯកិច្ចប្រជុំ GDCC លើកទី ១៦ ដែលថា អង្គការក្រៅរដ្ឋាភិបាល ជាអ្នកចូលរួមពេញលេញក្នុង CDCF ។ យើងខ្ញុំក៏ស្វាគមន៍ផងដែរដល់ការស្នើសុំអោយមានកិច្ចពិភាក្សាដាច់ដោយឡែកទៅលើតួនាទី នៃអង្គការក្រៅរដ្ឋាភិបាល ឬសង្គមស៊ីវិល នៅក្នុងក្រុមការងារបច្ចេកទេស ហើយពិនិត្យមើលឡើងវិញនូវ លក្ខ័ណ្ឌយោងរបស់ក្រុមការងារបច្ចេកទេស ដើម្បីឆ្លុះបញ្ចាំងពីសមាជិកភាព ។ យើងខ្ញុំត្រៀមខ្លួនជាស្រេច ដើម្បី ចូលរួមក្នុងកិច្ចពិភាក្សានេះ ទៅតាមវេលាសមស្របរបស់រដ្ឋាភិបាល ។

2010 AER ក៏បានសំដៅទៅលើតួនាទីរបស់រដ្ឋសភាក្នុងរបៀបវារៈប្រសិទ្ធភាពជំនួយ ។ មានការទទួលស្គាល់យ៉ាងទូលំទូលាយថា រដ្ឋសភាត្រូវដើរតួនាទីយ៉ាងសកម្មក្នុងការពង្រឹកភាពជាម្ចាស់របស់ជាតិ នៃរបៀបវារៈអភិវឌ្ឍ និងការត្រួតពិនិត្យមើលនូវលទ្ធផល នៃការអភិវឌ្ឍន៍ជំនួយ ។ តម្លាភាពនៅក្នុងបទបង្ហាញ នៃផែនការថវិកា រួមមានហិរញ្ញប្បទានផ្តល់ដោយដៃគូរអភិវឌ្ឍន៍ ព្រមទាំងសវនកម្ម ការត្រួតពិនិត្យ និងវាយតម្លៃ នៃការប្រើប្រាស់ប្រភពធនធានទាំងនេះ គឺជាតំរូវការចាំបាច់ដែលមិនអាចខ្វះបាន សម្រាប់រដ្ឋសភាបំពេញនូវតួនាទី ត្រួតត្រាមើលរបស់ខ្លួន ។ តួនាទីសមាជិករដ្ឋសភាកម្ពុជា ជាពិសេសស្ត្រី នៅក្នុងរបៀបវារៈប្រសិទ្ធភាពជំនួយមិនទាន់ ត្រូវបានសម្រេចបានពេញលេញនៅឡើយ ។ វាជាផ្នែកមួយដែលត្រូវតែពង្រឹងបន្ថែមទៀត ។

ដៃគូអភិវឌ្ឍន៍ស្វាគមន៍ចំពោះមតិយោបល់ពីរដ្ឋាភិបាល ថាតើរដ្ឋសភាអាចត្រូវបានផ្តល់តួនាទីកាន់តែខ្ពស់នៅក្នុងស្ថាប្បត្យករប្រសិទ្ធភាពជំនួយយ៉ាងដូចម្តេច ។ យើងខ្ញុំស្វាគមន៍នូវកិច្ចពិភាក្សាថាតើការអភិវឌ្ឍសមត្ថភាព

ក្នុងការវិភាគនូវប្រសិទ្ធភាពជំនួយ និងលទ្ធផលនៃការអភិវឌ្ឍន៍ ត្រូវជំរុញយ៉ាងដូចម្តេច ទាំងសម្រាប់សមាជិកគណៈកម្មាធិការពាក់ព័ន្ធ និងទាំងបុគ្គលិកគាំទ្ររបស់ពួកគេ ។

**ឯកឧត្តម លោក លោកស្រី !**

ជាទីបញ្ចប់ យើងខ្ញុំសូមថ្លែងអំណរគុណ CDC/CRDB ចំពោះការដឹកនាំដ៏ពូកែក្នុងការគាំទ្របណ្តាក្រសួង និងភ្នាក់ងារពាក់ព័ន្ធ ក្នុងទំនាក់ទំនង និងការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ ។ យើងខ្ញុំយល់ស្របថា គោលការណ៍នៃសេចក្តីថ្លែងការក្រុងប៉ារីស ត្រូវតែបន្តអោយទៅជារបៀបវារៈកំណែទំរង់រយៈពេលវែង ។ ទោះជាយ៉ាងណាក៏ដោយ សម្រាប់វេទិកាលើកទី៣នៃCDCFនេះ យើងខ្ញុំពង្រឹងនូវសារៈសំខាន់នៃការប្រកាន់យកវិធានការរួមគ្នា ដើម្បីបង្កើនភាពជាម្ចាស់របស់ប្រទេស ពង្រឹងការធ្វើសមាហរណកម្មនៃផែនការ ថវិកាជាតិ និងសម្របសម្រួលជំនួយអភិវឌ្ឍក្រៅប្រទេស ពង្រឹងភាពជាដៃគូរក្នុងកម្មវិធីតាមវិស័យរបស់យើង ផ្តោតការយកចិត្តទុកដាក់ទៅលើ ការអភិវឌ្ឍន៍សមត្ថភាព និងរបៀបវារៈកំណែទំរង់ចំនួនបី (កំណែទំរង់រដ្ឋបាលសាធារណៈ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការអភិវឌ្ឍន៍ប្រជាធិប្បតេយ្យថ្នាក់ក្រោមជាតិ) ដើម្បីលើកកំពស់ការផ្លាស់ប្តូរប្រកបដោយចីរភាពរយៈពេលវែង និងលទ្ធផលនៃការអភិវឌ្ឍ បង្កើនការចូលរួមជាមួយអង្គការសង្គមស៊ីវិល ឬអង្គការក្រៅរដ្ឋាភិបាល និងលើកកំពស់ការត្រួតពិនិត្យរបស់រដ្ឋសភាក្នុងផែនការ ការត្រួតពិនិត្យ និងការធ្វើថវិកាជាតិ ។

ប្រទេសកម្ពុជាមានវឌ្ឍនភាពគួរអោយកត់សំគាល់ នៅក្នុងប្រសិទ្ធភាពជំនួយ ដែលធានាអោយការគាំទ្រពីខាងក្រៅ ចូលរួមចំណែកដល់លទ្ធផលនៃការអភិវឌ្ឍប្រកបដោយគណនេយ្យភាព ។ រដ្ឋាភិបាល ស្ថិតនៅក្នុងកៅអីជាអ្នកបើកបរ ហើយយើងខ្ញុំជម្រុញអ្នកអោយរក្សាបាននូវសន្ទុះនេះ ។

**សូមអរគុណ !**